# ជំពូក ២: គោលនយោបាយ និង ការអនុវត្តន៍

## ២.១ សេចក្តីផ្តើម

ក្នុងឋានៈជានាយក ឬ ចៅកែរោងចក្រ លោកអ្នកមិនអាចត្រឹមតែមើលអំពីបញ្ហាផ្នែកសុវត្ថិភាព និងសុខភាពលើមូលដ្ឋានពិសេសនោះទេ ហើយសង្ឃឹមថាល័ក្ខខ័ណ្ឌនៅកន្លែងធ្វើការរបស់លោកអ្នកសមស្របតាមបទដ្ឋានជាតិ និងអន្តរជាតិនោះទេ។ វិធានការការពារ និងវិធានការទប់ស្កាត់ណាមួយដែលចាំបាច់ត្រូវដាក់ឱ្យអនុវត្តនៅកន្លែងធ្វើការ ត្រូវតែគ្រោងឡើងដោយប្រុងប្រយ័ត្ន ដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ទាំងអស់ និងផ្អែកលើគោលនយោបាយដែលមានចែងន័យច្បាស់លាស់ ហើយដែលអាចត្រូវបានគេអនុវត្ត វាយតំលៃ និងកែលំអជាប់រហូតនៅទូទាំងរោងចក្រ ។

ធាតុជាគន្លឹះនៃការគ្រប់គ្រងសុវត្ថិភាព និង សុខភាពប្រកបដោយជោគជ័យ គឺមានបង្ហាញជូននៅក្នុងរូបភាពទី១[២១] ។

<u>រូបភាពទី ១ :</u>




[២១] ដកស្រង់ចេញពីការគ្រប់គ្រងសុវត្ថិភាព និងសុខភាពប្រកបដោយជោគជ័យ របស់គណៈកម្មការប្រតិបត្តិផ្នែកសុវត្ថិភាព និងសុខភាព នៅចក្រភពអង់គ្លេស (១៩៩២)

## ២.២ ពត៌មានស្នូល

ចូរពិនិត្យមើលធាតុសំខាន់ៗជាគន្លឹះឱ្យកាន់តែពិស្តារ :

**<u>ការបង្កើតគោលនយោបាយ</u>** : ការគ្រប់គ្រងសុវត្ថិភាព និងសុខភាពប្រកបដោយប្រសិទ្ធិភាពតម្រូវឱ្យមានការបង្កើតឡើងនូវគោលនយោបាយទូលំទូលាយដែលពុំត្រឹមតែបំពេញតាមបទដ្ឋានជាតិ និងអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមចំណែកផ្តល់វិភាគទានដល់ការប្រកបអាជីវកម្មទាំងមូលនៃក្រុមហ៊ុនរបស់លោកអ្នក។ គោលនយោបាយស្តីពីសុវត្ថិភាព និងអនាម័យការងារ គឺជាផែនការរួម ឬជាវគ្គនៃសកម្មភាពដែលត្រូវអនុម័តយកសំរាប់ធ្វើការកែលំអសុខភាព និងសុវត្ថិភាពក្នុងរោងចក្រ។ សនិទានភាពនៅពីក្រោយគោលនយោបាយនេះ គឺថាវាត្រូវតែមានភាពច្បាស់លាស់ចំពោះរោងចក្ររបស់លោកអ្នក ហើយគប្បីកំណត់នូវបែបផែននៃការរៀបចំ និងនីតិវិធីចាំបាច់នានា ដើម្បីធានាអោយមានកន្លែងធ្វើការប្រកបដោយសុវត្ថិភាព និងអនាម័យ។ ម្យ៉ាងទៀតវាគប្បីបញ្ជាក់ច្បាស់ចំពោះសំនួរអំពីអ្នកណាខ្លះ អ្វីខ្លះ នៅពេលណា ហេតុអ្វី នៅកន្លែងណា និងដោយរបៀបយ៉ាងណាខ្លះ ដើម្បីឱ្យគ្រប់គ្នាយល់ដឹងអំពីវិធីអនុវត្តន៏ចំពោះសុខភាព និង សុវត្ថិភាពនៃរោងចក្ររបស់លោកអ្នក ព្រមទាំងចំលើយរបស់វា។ គោលនយោបាយនេះត្រូវចុះសោហ៊ុយតិចសំរាប់អនុវត្តន៏ ហើយមានគោលបំណងសំរេចឱ្យបានបរិយាកាសធ្វើការប្រកបដោយសុវត្ថិភាព និងអនាម័យ ដោយនៅពេលជាមួយគ្នានេះកាត់បន្ថយការខាតបង់ផ្នែកហិរញ្ញវត្ថុ និងបំណុល។ គោលនយោបាយនេះមានសារៈសំខាន់ ពីព្រោះវាតំណាងឱ្យផែនការសកម្មភាពជាមូលដ្ឋានសំរាប់ក្រុមហ៊ុនរបស់លោកអ្នកទាំងមូល ។

វាគប្បីមានរួមបញ្ចូលយ៉ាងហោចណាស់នូវគោលការណ៏គ្រឹះសំខាន់ៗ និងទិសដៅនានាដែលក្រុមហ៊ុនរបស់លោកអ្នកប្តេជ្ញាអនុវត្ត[២២] ។

- ការពារសុខភាព និងសុវត្ថិភាព សមាជិកបុគ្គលិកគ្រប់ៗគ្នាដោយការទប់ស្កាត់កុំឱ្យមានគ្រោះថ្នាក់ការងារ ការកើតមានបញ្ហាដោយគ្មានសុវត្ថិភាព សុខភាពមិនល្អ និងជំងឺ។
- អនុវត្តសមស្របតាមច្បាប់ និងតាមបទបញ្ជាពាក់ព័ន្ធទាំងអស់នៃប្រទេសកម្ពុជា (មើលបរិសិដ្ឋទី ១) អនុសញ្ញារួមណាមួយ ក្រមសីលធមិរបស់ម៉ូយទិញទំនិញទាក់ទងទៅនឹងសុវត្ថិភាព និងអនាម័យការងារ និងល័ក្ខខ័ណ្ឌការងារដែលត្រូវអនុវត្តចំពោះរោងចក្ររបស់លោកអ្នក ដ៏រាបណាក្រមសីលធមិនោះមិនផ្ទុយនឹងច្បាប់ជាតិ ។
- ធានាឱ្យប្រាកដថា កម្មករ និង តំណាងរបស់កម្មករត្រូវបានគេពិគ្រោះយោបល់ និងលើកទឹកចិត្តអោយចូលរួមយ៉ាងសកម្មនៅគ្រប់សមាសធាតុទាំងអស់នៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាព (ការចូលរួមរបស់កម្មករត្រូវបានគេមើលឃើញថាជាផ្នែកសំខាន់មួយនៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពប្រកបដោយជោគជ័យ) ។

[២២] គោលការណ៏ណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងអនាម័យការងារ ILO-OSH 2001

គោលនយោបាយស្តីពីសុវត្ថិភាព និង សុខភាពសំរាប់ក្រុមហ៊ុនរបស់លោកអ្នក គប្បីត្រូវធ្វើជាលាយលក្ខណ៍អក្សរ ខ្លីច្បាស់ ងាយយល់ដល់ភាគីពាក់ព័ន្ធទាំងអស់ មានការឯកភាពពីនាយក ឬពីគណៈកម្មការនាយក ហើយត្រូវយកទៅប្រាប់ដល់កម្មករទាំងអស់ អ្នកមើលការខុសត្រូវ (មេការ) និងនាយក ជាដើម ។ល ។ វាគប្បី :

- បែងចែកការទទួលខុសត្រូវផ្សេងៗគ្នាទៅលើសុវត្ថិភាព និង អនាម័យការងារដល់បុគ្គលិកចាត់តាំងផងដែរ ។
- បញ្ជាក់ពីការទទួលខុសត្រូវរបស់និយោជិក សិទ្ធិ និងភារកិច្ចរបស់កម្មករ និងពីសារៈសំខាន់នៃសកម្មភាពរួមក្នុងស្ថាប័នទាំងមូល ដូចជាគណៈកម្មការទទួលបន្ទុកផ្នែកសុវត្ថិភាព និង សុខភាព ។
- ធ្វើតាមទំរង់ និងសរសេរជាភាសាមួយដែលកម្មករទាំងអស់អាចយល់បាន ។ ក្នុងករណីដែលកំរិតចេះដឹងភាសានៅមានកំរិតទាប វិធីដោយឡែកមួយត្រូវតែប្រើប្រាស់ ដើម្បីពន្យល់អំពីគោលនយោបាយនេះ ។
- ត្រូវបិទផ្សាយពាសពេញរោងចក្រ និង ពន្យល់ឱ្យលំអិតដល់កម្មករថ្មីទាំងអស់ ។
- ត្រូវពិនិត្យសើរើជាប្រចាំដើម្បីដោះស្រាយបញ្ហាពិបាកថ្មីៗនៅកន្លែងធ្វើការ ឬធ្វើការកែលំអ បើការវាយតំលៃបង្ហាញថាគោលនយោបាយនេះមិនសំរេចតាមទិសដៅរបស់វា ឬតាមមិនទាន់បែបបទថ្មីនៃបច្ចេកវិទ្យា ដែលត្រូវយកមកប្រើ ឬមិនទាន់បានដាក់បញ្ចូលក្នុងគោលនយោបាយដែលកំពុងមានស្រាប់ ។



**រូបភាពទី២ : ការធ្វើផែនការដោយប្រយ័ត្នប្រយែងគឺតម្រូវឱ្យមាន នៅពេលរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងអនាម័យការងារ ប្រកបដោយប្រសិទ្ធិភាពនៅក្នុងរោងចក្ររបស់លោកអ្នក ។**

ដូច្នេះ បើក្រុមហ៊ុន ឬ រោងចក្ររបស់លោកអ្នកមានគោលនយោបាយស្តីពីសុវត្ថិភាព និង សុខភាពរួចហើយ ឬកំពុងតែដំណើរការបង្កើតគោលនយោបាយនេះ តើលោកអ្នកដឹងដោយរបៀបណាថាវាមានលក្ខណៈសមស្រប? ខាងក្រោមនេះ គឺជាសំនួរជាមូលដ្ឋានខ្លះៗ ដែលលោកអ្នកចាំបាច់ត្រូវសួរខ្លួនឯងនៅពេលពិនិត្យគោលនយោបាយនេះ[២៣] ។

[២៣] ដងស្រង់ចេញពីគោលការណ៍គ្រឹះស្តីពីសុវត្ថិភាព និងអនាម័យការងាររបស់ ILO 2001 និងពីគណៈកម្មការប្រតិបត្តិផ្នែកសុវត្ថិភាព និងសុខភាព ចក្រភពអង់គ្លេស សរសេរអំពីគោលនយោបាយ សុវត្ថិភាព : គោលការណ៍ណែនាំសំរាប់និយោជក (គ្មានកាលបរិច្ឆេទ)

- តើសេចក្តីថ្លែងនៃគោលនយោបាយនេះបញ្ជាក់ពីការប្តេជ្ញាចិត្តចំពោះសុវត្ថិភាព និងសុខភាពនៅក្នុងរោងចក្ររបស់លោកអ្នក ហើយកាតព្វកិច្ចរបស់លោកអ្នកចំពោះកម្មករបានធ្វើឱ្យច្បាស់លាស់ ឬទេ ?
- តើគោលនយោបាយនេះកំណត់ច្បាស់ទេ អំពីអ្នកណាខ្លះទទួលខុសត្រូវនៅគ្រប់កំរិតទាំងអស់នៃក្រុមហ៊ុនចំពោះការអនុវត្តន៍គោលនយោបាយ និងការពិនិត្យសើរើជាបន្ត? ជាងនេះទៀត តើវាមានបញ្ជាក់ពីរបៀបដែលត្រូវអនុវត្តឬទេ ?
- តើគោលនយោបាយមានចុះហត្ថលេខាដោយថៅកែ ឬនាយកគ្រប់គ្រង និងមានចុះកាលបរិច្ឆេទឬទេ?
- តើទស្សនៈរបស់នាយក ប្រធានមើលការខុសត្រូវ កម្មករ ឬតំណាងផ្នែកសុវត្ថិភាពរបស់គេ និងគណៈកម្មការសុវត្ថិភាព (បើមាន) ត្រូវបានគេលើកយកមកធ្វើការពិចារណាឬទេ ?
- តើភារកិច្ចមានចែង និងបែងចែកនៅក្នុងគោលនយោបាយដែលបានពិភាក្សា និងបានយល់ព្រមដោយមនុស្សដែលពាក់ព័ន្ធឬទេ? តើអ្នកទាំងនេះយល់ដឹងច្បាស់អំពីការទទួលខុសត្រូវ និងភារកិច្ចរបស់ខ្លួនឬទេ? តើពេលវេលាប៉ុន្មានដែលពួកគេបានលៃទុកសំរាប់អនុវត្តភារកិច្ចទាំងនេះ ហើយតើធនធានអ្វីខ្លះដែលពួកគេមានសំរាប់ប្រើប្រាស់ ។
- តើគោលនយោបាយមានយោងសេចក្តីសំអាងចំពោះសារៈសំខាន់នៃការចូលរួមរបស់កម្មករ និងការសហការរបស់កម្មករឬទេ? ឧទាហរណ៍ : តើវាយោងទៅតាមកម្មករដែលចូលរួមក្នុងការត្រួតពិនិត្យរួមគ្នា ឬតាមសមាជិកសកម្មនៃគណៈកម្មការទទួលបន្ទុកផ្នែកសុវត្ថិភាព និងសុខភាពឬទេ ។
- តើវាមានចែងអំពី អ្នកណាខ្លះទទួលខុសត្រូវចំពោះបញ្ហានានាដូចតទៅនេះ និងអ្នកណាខ្លះត្រូវជំនួសមនុស្សដែលគេចាត់តាំងអោយទទួលភារកិច្ច បើគាត់អវត្តមានពីការងារ ។
  - ធ្វើរបាយការណ៍អំពីការស៊ើបអង្កេត និង កត់ត្រាអំពីគ្រោះថ្នាក់
  - ការព្រមានជាមុនអំពីអគ្គីភ័យ ការហ្វឹកហាត់អំពីអគ្គីភ័យ នីតិវិធីជំលៀសខ្លួនចេញ
  - ការសង្គ្រោះបឋម
  - ការបណ្តុះបណ្តាល ។ល ។

ដូច្នេះវាជាការមានប្រយោជន៍ក្នុងការរំលឹកឡើងវិញថា គោលនយោបាយស្តីពីសុវត្ថិភាព និងសុខភាពរបស់លោកអ្នក គឺផែនការសកម្មភាពជាមូលដ្ឋានដែលផ្សារភ្ជាប់កិច្ចការ និងការរៀបចំអនុវត្តទៅនឹងមនុស្សមួយចំនួននៅក្នុងរោងចក្ររបស់លោកអ្នក ដើម្បីធានាអោយបានថាកន្លែងធ្វើការមានសុវត្ថិភាព និងអនាម័យ ។ ក្រៅពីការបំពេញបានតាមការតម្រូវផ្នែកច្បាប់នៃប្រទេសកម្ពុជា ដូចមានចែងនៅក្នុងបទបញ្ជាពាក់ព័ន្ធ និងបទដ្ឋានការងារដែលមានចែងក្នុងលិខិតបទដ្ឋានអន្តរជាតិនានា និងក្រមសីលធម៌នៃម៉ូយទិញទំនិញ គោលនយោបាយគិតដោយល្អិតល្អន់ដែលត្រូវ

បានរៀបចំឡើង ដោយមានការពិគ្រោះយោបល់ជាមួយបណ្តាភាគីពាក់ព័ន្ធទាំងអស់ អាចនាំមកនូវផលប្រយោជន៏ខាងការប្រកួតប្រជែងពិត១ និងនាំមកនូវអត្ថប្រយោជន៏ខាងសង្គម ។

**ការរៀបចំ - ការទទួលខុសត្រូវ និងភាពទទួលខុសត្រូវ :**

វាពុំមែនជាការល្អទេដែលមានគោលនយោបាយដ៏ល្អ តែនៅលើក្រដាស បើសិនណាជាគោលនយោបាយនេះពុំត្រូវបានយកទៅអនុវត្ត ហើយការអនុវត្តន៏ទាមទាមឱ្យមានការរៀបចំ។ ប្រការនេះពាក់ព័ន្ធដល់ការបង្កើតឡើងនូវការទទួលខុសត្រូវ និងសម្ព័ន្ធការដែលលើកស្ទួយវប្បធម៌នៃសុវត្ថិភាព និងសុខភាពនៅពេញរោងចក្រទាំងមូលតាំងពីថ្នាក់លើដល់ថ្នាក់ក្រោម។ វាត្រូវតែមានការបញ្ជាក់ថា និយោជក គឺជាអ្នកមានភារៈទទួលខុសត្រូវទាំងស្រុងចំពោះកិច្ចការពារដល់សុវត្ថិភាព និងសុខភាពរបស់កម្មករ និយោជិត។ ក្នុងឋានៈជាថៅកែ ឬនាយករោងចក្ររបស់លោកអ្នក គឺស្រេចតែលោកអ្នកទេ ក្នុងការផ្តល់នូវការដឹកនាំសំរាប់សកម្មភាពនៃសុខភាព និងសុវត្ថិភាព។ បន្ទាប់ពីមានការពិគ្រោះយោបល់ និងការឯកភាពជាមួយបណ្តាភាគីពាក់ព័ន្ធទាំងអស់ វាជាភារកិច្ចរបស់លោកអ្នកក្នុងការបែងចែកការទទួលខុសត្រូវ ភាពទទួលខុសត្រូវ និងអំណាចសំរាប់ការបង្កើតការអនុវត្តន៏ និងការប្រព្រឹត្តទៅនៃគោលនយោបាយស្តីពីសុវត្ថិភាព និងសុខភាពរបស់លោកអ្នក។ ប្រការនេះមានរួមទាំងការធានាអោយប្រាកដថា សុខភាព និងសុវត្ថិភាព គឺជាការទទួលខុសត្រូវនៃអ្នកគ្រប់គ្រងតាមផ្នែកដែលត្រូវបានគេដឹង និងទទួលយកនៅគ្រប់កំរិតទាំងអស់ក្នុងការបង្កើតឡើងនូវការរៀបចំអនុវត្តន៏ការងារប្រកបដោយប្រសិទ្ធិភាពដើម្បីកំណត់ វាស់ស្ទង់ (បើអាចធ្វើបាន) និងទប់ស្កាត់ហានិភ័យការងារ និងគ្រោះថ្នាក់ការងារ ហើយលើកកំពស់សុខភាពនៅក្នុងការងារ។ វាក៏ជាការទទួលខុសត្រូវរបស់លោកអ្នកដែរក្នុងការធានាអោយបានថា ការរៀបចំនានាត្រូវធ្វើឡើងសំរាប់ការចូលរួមពេញលេញរបស់កម្មករនិយោជិត និងតំណាងរបស់ពួកគេនៅក្នុងការបង្កើត និងការអនុវត្តន៏នូវគោលនយោបាយស្តីពីសុវត្ថិភាព និងសុខភាព។ ធនធានសមល្មម (ពេលវេលា ប្រាក់កាស ការបណ្តុះបណ្តាលជាដើម) ត្រូវតែផ្តល់អោយ ទើបកម្មករនិយោជិតទាំងអស់នោះដែលជាអ្នកត្រូវបានគេផ្តល់ការទទួល ខុសត្រូវអោយនៅក្នុងរោងចក្រ អាចអនុវត្តភារកិច្ចរបស់ខ្លួនបានយ៉ាងសក្តិសិទ្ធិ ។ ផ្នែកផ្សេង១ទៀតមាន :

- ជួយបង្កើតគណៈកម្មការរួមទទួលបន្ទុកផ្នែកសុវត្ថិភាព និងសុខភាព។
- ធានាថា មនុស្សដែលត្រូវបានគេចាត់តាំងឡើងមកមានសមត្ថភាពសមស្រប ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនស្តីពីសុវត្ថិភាព និងសុខភាព ។
- ធានាថា ការបណ្តុះបណ្តាលជាចាំបាច់ស្តីពីសុខភាព និងសុវត្ថិភាព ត្រូវបានអនុវត្តនៅទូទាំងរោងចក្រ ដោយគ្មានយកប្រាក់ពីកម្មករ។
- ធ្វើអោយប្រាកដថា កម្មករទាំងអស់បានយល់ដឹងពីគោលនយោបាយនេះ ហើយអាចកំណត់បានថា អ្នកណាជាអ្នកទទួលខុសត្រូវចំពោះផ្នែកណាខ្លះ ទើបបញ្ហាកើតឡើង អាចត្រូវបានគេរាយការណ៏ប្រាប់។

- រក្សាទុកកំណត់ត្រាទាំងស្រុងអំពីអធិការកិច្ច គ្រោះថ្នាក់ សុខភាពមិនល្អជាដើម ។ល។
- សុំពីអ្នកផ្គត់ផ្គង់ទំនិញនូវពតិមានលំអិតពេញលេញអំពីផលិតផលដែលត្រូវប្រើ (ឧទាហរណ៍ : តារាងទិន្នន័យសុវត្ថិភាពអំពីវត្ថុធាតុគីមីទាំងអស់មានប្រើក្នុងរោងចក្រ) ។
- ផ្តល់ការប្រាស្រ័យទាក់ទងតាមប្រព័ន្ធពីរផ្លូវចំពោះការណ៏នេះ អ្នកគ្រប់គ្រងជាន់ខ្ពស់អាចរាយការណ៏ប្រាប់អំពីបញ្ហាសុវត្ថិភាព និងសុខភាព ដល់កម្លាំងពលកម្ម និងពីកម្លាំងពលកម្មទៅជូនថ្នាក់ដឹកនាំជាន់ខ្ពស់វិញ។
- ធានាថា សុខភាព និងសុវត្ថិភាពនៅក្នុងរោងចក្រ គឺជាសកម្មភាពដែលកំពុងបន្តប្រកបដោយថាមភាពនៅក្នុងរោងចក្រ ហើយមិនមែនទើបតែចាប់ធ្វើនៅពេលដែលមានការចុះពិនិត្យដោយអធិការការងារដោយអ្នកតាមឃ្លាំមើលរបស់ ILO ឬ ដោយអ្នកពិនិត្យអំពីភាពសមស្របនៃម្ចាស់ទំនិញទេ ។

**ចូរចងចាំ :**

១- អ្នកគ្រប់គ្រងពុំមានតួនាទីក្នុងការជ្រើសរើសតំណាងណាមួយរបស់កម្មករមកធ្វើជាសមាជិកនៃគណៈកម្មការរួមទទួលបន្ទុកផ្នែកសុវត្ថិភាព និងសុខភាពទេ។ គឺវាស្រេចតែលើកម្មករជាអ្នកជ្រើសរើសតំណាងផ្ទាល់របស់គេ។

២- ក្រុមហ៊ុនខ្លះនិយាយថា "គេយកចិត្តទុកដាក់ខ្លាំងណាស់ចំពោះសុវត្ថិភាព និងសុខភាព" ពីព្រោះគេមាន "មន្ត្រីទទួលបន្ទុកផ្នែកសុវត្ថិភាព"។ ជានិច្ចកាលមន្ត្រីសុវត្ថិភាពទាំងអស់នេះគឺជាបុគ្គលដែលធ្វើការតែម្នាក់ឯង ហើយមានការបណ្តុះបណ្តាលតិចតួច ឬគ្មានការបណ្តុះបណ្តាលអំពីសុខភាព និងសុវត្ថិភាពទេ។

## ការធ្វើផែនការនិងការអនុវត្តន៍:

ដោយបានបង្កើតឱ្យមានគោលនយោបាយ និងបានធ្វើការរៀបចំសំរាប់ការអនុវត្តន៍រួចហើយឥឡូវនេះជាពេលត្រូវអនុវត្តគោលនយោបាយនេះ។ ប្រការនេះទាមទារឱ្យមានការធ្វើផែនការដោយប្រុងប្រយ័ត្ន និងការសំរបសំរួលដើម្បីសំរេចបានជោគជ័យ។ កិច្ចការនេះទាក់ទងនឹងការពិនិត្យមើល រោងចក្ររបស់លោកអ្នក ជាលើកដំបូងដោយប្រើ បញ្ជីផ្ទៀងផ្ទាត់ដែលមានផ្តល់ជូនជាមួយនឹងសៀវភៅណែនាំនេះ ដើម្បីកំណត់អំពី :

- របៀបត្រូវអនុវត្តច្បាប់ជាតិបច្ចុប្បន្ន បទដ្ឋានអន្តរជាតិ និងក្រមសីលធម៌របស់ម៉ូយទិញទំនិញ បើមាន ។
- អ្វីខ្លះជាគ្រោះថ្នាក់ និងហានិភ័យចំពោះសុខភាព និងសុវត្ថិភាពដែលអាចមាននៅក្នុងរោងចក្ររបស់លោកអ្នក (មើលផ្នែកស្តីពីការធ្វើផែនទីហានិភ័យ និងការប្រើបញ្ជីផ្ទៀងផ្ទាត់) ។
- វិធានការទប់ស្កាត់ណាមួយដែលអាចមានស្រាប់ ហើយវាយតំលៃអំពីប្រសិទ្ធិភាពរបស់វា ។
- ក៏រិតនៃការការពារគ្រោះអាសន្ន ការត្រៀមលក្ខណៈ និងពេលវេលាត្រូវទប់ទល់ (ឧទាហរណ៍ : ដូចជាករណីអគ្គីភ័យក្នុងរោងចក្រ) ។

- វិភាគទិន្នន័យពីសៀវភៅកត់ត្រាគ្រោះថ្នាក់ និងជំងឺ
- ការរៀបចំសំរាប់ការផ្តល់ការសង្គ្រោះបឋម
- មានការរៀបចំអ្វីខ្លះ ឬ តើចាំបាច់ត្រូវប្រើវាដើម្បីធានាឱ្យមានការពិគ្រោះយោបល់ ការសហការ និងជាសំខាន់បំផុត ការចូលរួមរបស់កម្មករ ។
- ការរៀបចំជាពិសេសណាមួយ ចាំបាច់សំរាប់លទ្ធកម្មនៃទំនិញ និងសេវាកម្ម
- ការរៀបចំជាពិសេសណាមួយ សំរាប់អ្នកម៉ៅការបន្ត ការីយភារីនៅការដ្ឋាន ឬ ភ្ញៀវមកទស្សនារោងចក្រ ។

ក្រោយពីការពិនិត្យជាដំបូងកើតឡើងរួចហើយ (អាចចំណាយពេលបួនប្រាំថ្ងៃក្នុងការធ្វើសាវនកម្មរោងចក្រទាំងអស់អោយបានល្អិតល្អន់) ។ វាមានសារៈសំខាន់ក្នុងការកាត់បន្ថយហានិភ័យចំពោះសុវត្ថិភាព និងសុខភាព ដោយតាក់តែងផែនការ កំណត់អាទិភាពដោយផ្អែកទៅលើហានិភ័យពាក់ព័ន្ធ កំណត់បទដ្ឋានអនុវត្តន៍ការងារសំរាប់សកម្មភាពរបស់អ្នកគ្រប់គ្រង និងបង្កើតនូវកាលវិភាគប្រាកដនិយមមួយ ។ ប្រការនេះផ្តល់អោយលោកអ្នកនូវបន្ទាត់មូលដ្ឋានសំរាប់វាស់វែងបទដ្ឋានទាំងអស់ក្នុងអនាគត ។

## ការវាយតំលៃ

វាមានសារៈសំខាន់ជាសារវ័ន្តសំរាប់តាមឃ្លាំមើលការប្រតិបត្តិផ្នែកសុវត្ថិភាព និងសុខភាពរបស់លោកអ្នកជាប្រចាំ។ ជានិច្ចកាល វឌ្ឍនភាពល្អកាលដើមទី និងអំណរសាទរចុះថយ ហើយបទដ្ឋានក៏រអិលជ្រុះ។ វាអាស្រ័យលើអ្នក គ្រប់គ្រងក្នុងការបង្កើតនីតិវិធីសំរាប់ពិនិត្យវាស់ស្ទង់ និងកត់ត្រាអំពីការប្រតិបត្តិផ្នែកសុវត្ថិភាព និងសុខភាពនៅក្នុងរោងចក្រ។ នីតិវិធីទាំងនេះ អាចពាក់ព័ន្ធនឹងការពិនិត្យមើលជាប្រចាំដោយសមាជិកនៃគណៈកម្មការ ទទួលបន្ទុកផ្នែកសុវត្ថិភាព និងសុខភាព ដោយមានការស្វែងរកយោបល់ណែនាំពីអធិការដ្ឋានការងារ ដោយធ្វើវិភាគទិន្នន័យដូចជា កំណត់ត្រាអំពីជំងឺ និងគ្រោះថ្នាក់ ។ ក្រុមហ៊ុនដែលមានសៀវភៅកត់ត្រាល្អអំពីសុខភាព និងសុវត្ថិភាពធ្វើការវាស់ស្ទង់អំពីការអនុវត្តន៍របស់ខ្លួនជាប្រចាំធៀបទៅនឹងផែនការដែលបានកំណត់ជាមុន និងធៀបទៅនឹងបទដ្ឋានដែលបានឯកភាព ហើយបន្ត "មធ្យោបាយដ៏ពិសិដ្ឋ" ដើម្បីកែលំអការអនុវត្តន៍ ។

បញ្ជីផ្ទៀងផ្ទាត់ផ្តល់ជូននៅខាងក្រោមនេះនឹងជួយលោកអ្នកវាយតំលៃអំពីកំរិតនៃការត្រៀមលក្ខណៈជាស្រេចនៃ ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពនៅក្នុងរោងចក្ររបស់លោកអ្នក។ បើលោកអ្នកឆ្លើយថា " ទេ " ចំពោះសំណួរភាគច្រើនក្នុងចំណោមសំនួរទាំងនេះ លោកអ្នកនឹងចាំបាច់ត្រូវចាត់វិធានការ។ ប្រភេទនៃវិធានការ ឬ សកម្មភាពអាចកត់សំគាល់ដាក់ក្នុងប្រអប់នៃ "**សកម្មភាពត្រូវអនុវត្ត**"។

## ២.៣. គោលនយោបាយ និងបញ្ជីផ្ទៀងផ្ទាត់ការអនុវត្តន៍

| | បាទ ចាស | ទេ | សកម្មភាព ត្រូវអនុវត្ត |
|---|---|---|---|
| តើរោងចក្រមានគោលនយោបាយស្ដីពីសុវត្ថិភាព និងអនាម័យការងារ ជាលាយលក្ខណ៍អក្សរឬទេ? | | | |
| តើមានអ្នកណាខ្លះចេញពីជួរថ្នាក់ដឹកនាំជាន់ខ្ពស់ ដែលមានភារៈទទួលខុសត្រូវអនុវត្តគោលនយោបាយនេះ? | | | |
| តើមានថវិកាដោយឡែកទុកសំរាប់អនុវត្តគោលនយោបាយនេះឬទេ? | | | |
| តើមានច្បាប់ចំលងនៃគោលនយោបាយនេះ ដាក់តាំងនៅក្នុងរោងចក្រឬទេ? | | | |
| តើមានច្បាប់ចំលងនៃគោលនយោបាយនេះ ជាភាសាក្នុងស្រុក និងមានពន្យល់ប្រាប់ដល់កម្មករនិយោជិតឬទេ? | | | |
| តើមានការពិគ្រោះយោបល់ជាមួយកម្មករនិយោជិត អំពីការតាក់តែងគោលនយោបាយនេះឬទេ? | | | |
| តើមានគណៈកម្មការទទួលបន្ទុកផ្នែកសុវត្ថិភាព និងអនាម័យ នៅក្នុងរោងចក្រឬទេ? | | | |
| តើមានកម្មករនិយោជិតចូលរួមក្នុងគណៈកម្មការនេះឬទេ? | | | |
| តើកម្មករនិយោជិតទាំងអស់ទទួលការបណ្ដុះបណ្ដាលស្ដីពីសុវត្ថិភាព និងអនាម័យ ហើយមានការយល់ដឹងអំពីប្រការទាំងឡាយនៃគោលនយោបាយនេះឬទេ? | | | |
| តើមានអ្នកតំណាងផ្នែកសុវត្ថិភាព ( ជាថ្នាក់ដឹកនាំ ឬកម្មករនិយោជិត) នៅក្នុងរោងចក្រឬទេ? | | | |
| តើអ្នកតំណាងផ្នែកសុវត្ថិភាពទាំងនេះបានទទួលការបណ្ដុះបណ្ដាលឬទេ? | | | |
| តើរោងចក្រនេះត្រូវបានគ្របដណ្ដប់ដោយ " ក្រិត្យបញ្ញត្តិណាមួយស្ដីពីរោងចក្រ " នៃប្រទេសកម្ពុជាឬទេ? | | | |

| | | | |
|---|---|---|---|
| តើថ្នាក់ដឹកនាំរោងចក្រ និងកម្មករនិយោជិត បានដឹងអំពីបទប្បញ្ញត្តិស្ដីពីសុខភាព និងសុវត្ថិភាពឬទេ? | | | |
| តើថ្នាក់ដឹកនាំរោងចក្រ និងកម្មករនិយោជិត មានទទួលបានច្បាប់ចំលងនៃច្បាប់ ឬបទបញ្ជាទាក់ទងនឹងសុវត្ថិភាព និងអនាម័យការងារឬទេ? | | | |
| តើធ្លាប់មានមន្ត្រីពីអធិការដ្ឋានការងារ បានចុះទស្សនកិច្ចពិនិត្យមើលទីកន្លែងធ្វើការឬទេ ក្នុងរយៈពេល ១២ខែ កន្លងទៅនេះ? | | | |
| តើធ្លាប់មានការហាមប្រាម ឬការដាក់កំហិតឱ្យកែលំអណាមួយ ត្រូវបានគេធ្វើឡើងដោយអធិការដ្ឋានការងារចំពោះរោងចក្រឬទេ? | | | |
| តើរោងចក្រត្រូវបានគ្របដណ្តប់ដោយក្រមសីលធម៌នៃម្ចាស់យីហោណាមួយឬទេ? | | | |
| តើម៉ូយទិញទំនិញមានចុះពិនិត្យរោងចក្រ ដើម្បីធានាឱ្យមានភាពសមស្រប នៅក្នុងវិស័យសុវត្ថិភាព និងអនាម័យឬទេ? | | | |

## ២.៤ សេចក្តីសង្ខេប

ចូរចងចាំថា ការដាក់អោយប្រើនូវប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពដ៏ល្អមួយមិនត្រឹមតែកែលំអឱ្យប្រសើរនូវល័ក្ខខ័ណ្ឌការងារសំរាប់កម្មករនិយោជិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានឥទ្ធិពលជាវិជ្ជមានទៅលើបញ្ជីតារាងតុល្យភាពតាមរយៈការបង្កើនផលិតភាព សុខភាពមិនល្អកើតមានតិចតួច គ្រោះថ្នាក់តិចតួច កំលាំងចិត្តរបស់បុគ្គលិកឡើងខ្ពស់ ការផ្លាស់ប្តូរបុគ្គលិកមានតិច និងកិត្តិស័ព្ទវិជ្ជមានចំពោះម៉ូយទិញទំនិញ ។

ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពមួយប្រកបដោយជោគជ័យ ត្រូវមានរួមផ្សំនូវ :

- ការបង្កើតនូវគោលនយោបាយ
- ការរៀបចំអនុវត្តន៍ - ការទទួលខុសត្រូវ និងភាពទទួលខុសត្រូវ
- ការធ្វើផែនការ និងការអនុវត្តន៍
- ការវាយតំលៃ

ប្រការនេះទាមទារអោយមានការពិគ្រោះយោបល់ ការសហការ និងការប្តេជ្ញាចិត្តពីគ្រប់បណ្តាភាគីពាក់ព័ន្ធទាំងអស់។ ការចូលរួមរបស់កម្មករ ត្រូវបានគេមើលឃើញថា ជាផ្នែកដ៏សំខាន់មួយនៃដំណើរការនេះ ។

អាជ្ញាធរខ្លះផ្តល់គោលការណ៍ណែនាំអំពីការរៀបចំគោលនយោបាយស្តីពីសុវត្ថិភាព និងសុខភាព។ ឧទាហរណ៍មួយគឺបានមកពីគណៈកម្មការប្រតិបត្តិផ្នែកសុវត្ថិភាព និងសុខភាព នៅចក្រភពអង់គ្លេស ដូចមានផ្តល់ជូននៅក្នុងបរិសិដ្ឋទី ២។